# ការរៀបចំផែនការអភិវឌ្ឍន៍បញ្ចេញកាបូនតិច ឆ្ពោះទៅរកឆ្នាំ២០៥០ នៅកម្ពុជា

តាមការព្យាករណ៍បង្ហាញថាចំនួនប្រជាជនកម្ពុជានឹងកើនឡើងពីប្រហែល១៤លាននាក់នៅឆ្នាំ២០១០ រហូតដល់ចំនួនប្រហែល ១៨លាន និង ២២លាន នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ រាជរដ្ឋាភិបាលមានមហិច្ឆតាជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឆ្ពោះទៅរកប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ រាជរដ្ឋាភិបាលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យដ៏សំខាន់រួមចំណែកដល់ផលិតផលក្នុងស្រុកសរុប (GDP)។ ទាក់ទងនឹងវិស័យថាមពលវិញ រាជ-រដ្ឋាភិបាលបានកំណត់គោលដៅដើម្បីផ្តល់ថាមពលអគ្គិសនីអោយបាន ១០០% នៃចំនួនភូមិទាំងអស់ត្រឹមឆ្នាំ២០២០ និង ចំនួន ៧០% នៃចំនួនលំនៅដ្ឋានសរុបត្រឹមឆ្នាំ២០៣០ ហើយថាមពលវារីអគ្គីសនី គឺជាប្រភពផ្តល់ថាមពលមួយដ៏សំខាន់។ រាជរដ្ឋាភិបាលក៏បានប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីរក្សាគម្របព្រៃឈើអោយបាន ៦០% ត្រឹមឆ្នាំ២០១៥។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលបានអនុម័តនូវបរិធានគតិយុត្តិមួយចំនួនសម្រាប់គ្រប់គ្រងសំណល់ (ឧ.គោលការណ៍ ៣Rs និង អនុក្រឹត្រស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី) ដើម្បីកាត់បន្ថយការបង្កើតសំណល់នៅតាមប្រភព និងការបោះចោលសំណល់នៅតាមទីលានសំរាម។

កម្ពុជាជាប្រទេសដែលមានបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចតួចបំផុត ដោយបរិមាណបញ្ចេញសម្រាប់មនុស្សម្នាក់ៗមានតែ ០.២៣tCO$_2$eq./year ប៉ុណ្ណោះក្នុងឆ្នាំ២០០០។ ក្នុងនោះ វិស័យប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ (LUCF) បានបញ្ចេញចំនួន ៥១% នៃបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប ហើយវិស័យកសិកម្មបញ្ចេញចំនួន ៤៥% វិស័យថាមពលបញ្ចេញចំនួន ៤% និង វិស័យសំណល់បញ្ចេញចំនួនមិនដល់ ១% ផង។ ទោះបីជា បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានចំនួនតិចតួចបើប្រៀបធៀបនៅនឹងបរិមាណបញ្ចេញសរុបរបស់ពិភពលោកក៏ដោយ ក៏កម្ពុជាបានប្តេជ្ញាចិត្តអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនឆ្ពោះទៅរកសង្គមមួយប្រកបដោយភាពបៃតង មានការបញ្ចេញកាបូនតិច ធន់នឹងអាកាសធាតុ ប្រកបដោយសមធម៌ ចីរភាព និងផ្អែកលើចំណេះដឹង។

តាមការព្យាករណ៍បង្ហាញថា បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជានឹងកើនឡើងពីចំនួន ៤.៨៤៧ktCO$_2$eq./year (គីឡូតោននៃសមមូលកាបូនក្នុងមួយឆ្នាំ) រហូតដល់ ២០.២៤៥ (៤ដង) និង ១២០.៥២៣ ktCO$_2$eq./year (២៥ ដង) នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ តាមរយៈការអនុវត្តគោលនយោបាយចំនួន ៤ (បួន) និងយុទ្ធសាស្ត្រចំនួន ១២ (ដប់ពីរ) រួមជាមួយសកម្មភាពសំខាន់ៗមួយចំនួននោះ ប្រទេសកម្ពុជាអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានប្រហែល ៣៨.០៣៩ និង ៨៧.៤៦២ ktCO$_2$eq./year នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ គោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះនឹងរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយផ្ទាល់និងដោយប្រយោល។

**ទី១៖** គោលនយោបាយស្តីពី សុខដមនីយកម្មរវាងសេដ្ឋកិច្ច សង្គម និងវប្បធម៌បៃតងដែលគ្របដណ្តប់លើយុទ្ធសាស្ត្រចំនួន ៦ (ប្រាំមួយ) អាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់ ៣០% និង ៥៤% នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។

**ទី២៖** គោលនយោបាយស្តីពី បរិស្ថានបៃតងដែលគ្របដណ្តប់លើយុទ្ធសាស្ត្រចំនួន ៣ (បី) អាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់ ៦៦% និង ៤០% នៅឆ្នាំ 2030CM និង 2050CM រៀងៗខ្លួន។

**ទី៣៖** គោលនយោបាយស្តីពី ភូមិបៃតងដែលគ្របដណ្តប់លើយុទ្ធសាស្ត្រចំនួន ២ (ពីរ) អាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានតែ ៤% និង ៦% នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។

**ទី៤៖** គោលនយោបាយស្តីពី សេដ្ឋកិច្ចបៃតងអាចរួមកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយប្រយោល។ ប៉ុន្តែ គោលនយោបាយនេះដើរតួនាទីយ៉ាងសំខាន់ដើម្បីរួមចំណែកសម្រេចបានគោលដៅកាត់បន្ថយសរុប។ គោលនយោបាយនេះគ្របដណ្តប់លើយុទ្ធសាស្ត្រស្តីពីជំនួញនាវាសមុទ្របៃតង និងការគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយចីរភាពតែមួយប៉ុណ្ណោះ។ តារាងទី១ បង្ហាញពីគោលនយោបាយនិងយុទ្ធសាស្ត្រនិងបរិមាណកាត់បន្ថយ។

**តារាងទី១៖** គោលនយោបាយចំនួន ៤ (បួន) និងយុទ្ធសាស្ត្រចំនួន ១២ (ដប់ពីរ) រួមទាំងបរិមាណកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ [ktCO$_2$eq./year]

| **គោលនយោបាយចំនួន ៤ និងយុទ្ធសាស្ត្រចំនួន ១២** [ktCO$_2$eq./year] | **កូដ** | **ការពន្យល់** | **បរិមាណកាត់បន្ថយ** * | |
|---|---|---|---|---|
| | | | 2030CM | 2050CM |
| **គោលនយោបាយស្តីពីសុខដមនីយកម្មរវាងសេដ្ឋកិច្ច សង្គមនិង វប្បធម៌បៃតង** | PGH | | **១១.៤០៩** | **៤៧.២៤៦** |
| អភិបាលកិច្ចល្អនិងការអភិវឌ្ឍធនធានមនុស្សបៃតង (ការកាត់បន្ថយដោយប្រយោល) | GGG | ការអនុវត្តស្ថាប័នបៃតងនិងការចូលរួមរបស់យុវជនដើម្បីគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាន | | |
| ការគ្រប់គ្រងទេសចរណ៍បៃតង (ការកាត់បន្ថយដោយប្រយោល) | GTM | ការផ្សព្វផ្សាយអំពីការកាត់បន្ថយសំណល់និងការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសាធារណៈដល់ភ្ញៀវទេសចរ | | |
| ការកៀរគរធនធានហិរញ្ញវត្ថុបៃតង (ការកាត់បន្ថយដោយប្រយោល) | GFM | ការវិនិយោគទុនលើកិច្ចការពារធនធានធម្មជាតិនិងថាមពលកកើតឡើងវិញ | | |
| ការអភិវឌ្ឍវិស័យថាមពលបៃតង | GEN | ការប្រើប្រាស់ឧបករណ៍ប្រសិទ្ធភាពថាមពលនិងថាមពលកកើតឡើងវិញ | ៤.២៨១ | ១៦.៥៥៩ |
| ការអភិវឌ្ឍបច្ចេកវិទ្យានិងវិនិយោគទុនបៃតង | GTI | ការវិនិយោគទុនបច្ចេកវិទ្យាបៃតង (ឧ. ថាមពលពន្លឺព្រះអាទិត្យ) | ១.៤៤៣ | ៤.៩២៧ |
| ការអភិវឌ្ឍវិស័យដឹកជញ្ជូនបៃតង | GTN | ការនាំចូលនូវយានយន្តប្រសិទ្ធភាពថាមពលនិងការអនុវត្តប្រព័ន្ធដឹកជញ្ជូនសាធារណៈ | ៥.៦៨៥ | ២៥.៧៦១ |
| **គោលនយោបាយស្តីពីបរិស្ថានបៃតង** | PGE | | **២៥.២១២** | **៣៥.៣១** |
| ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព | SFM | ការគ្រប់គ្រងនិងដាំដើមឈើឡើងវិញប្រកបដោយប្រសិទ្ធភាព | ៨.៨៨៩ | ៨.៨៨៦ |
| ការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព | SWM | ការអនុវត្តគោលការណ៍ ៣Rs និងការចាប់យក CH4 ពីទីលានសំរាម | ៧៥១ | ៥.៨៧៤ |
| ការគ្រប់គ្រងកសិកម្មបៃតង | GAM | ការអនុវត្តការផ្លាស់ប្តូរទឹកស្រែពាក់កណ្តាលរដូវ និងការចិញ្ច្រាំគល់ជញ្ជ្រាំងស្រូវក្រោយការប្រមូលផលស្រូវ | ១៥.៥៧២ | ២០.៥៥ |
| **គោលនយោបាយស្តីពីភូមិបៃតង** | PEV | | **១.៤១៧** | **៤.៩០៧** |
| ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយការបញ្ចេញកាបូនតិច | LCI | ការរៀបចំផ្លូវដើរក្នុងតំបន់ទីក្រុង និងការផ្លាស់ប្តូរប្រព័ន្ធដឹកជញ្ជូន (modal shift) | ១.០៨៤ | ៣.៦១៨ |
| ការកសាងសំណង់អាគារបៃតង | GB | ការអនុវត្តការសាងសង់សំណង់អាគារបៃតងនិងការសន្សំសំចៃថាមពល | ៣៣៣ | ១.២៨៩ |
| **គោលនយោបាយស្តីពីសេដ្ឋកិច្ចខៀវ** (**ការកាត់បន្ថយដោយប្រយោល**) | PBE | | | |
| ជំនួញនាវាសមុទ្របៃតងនិងការគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយចីរភាព | CZM | ការគ្រប់គ្រង ការពារ និងដាំដើមកោងកាងឡើងវិញ | | |
| **បរិមាណកាត់បន្ថយសរុប** | | | **៣៨.០៣៩** | **៨៧.៤៦២** |

*បរិមាណកាត់បន្ថយទាំងនេះប្រៀបធៀបទៅនឹង ២០.២៤៥ និង ១២០.៥២៣ ktCO$_2$eq./year នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ BaU= ការអភិវឌ្ឍតាមទម្លាប់; CM= ការអភិវឌ្ឍដោយអនុវត្តន៍វិធានការកាត់បន្ថយ

IGES · KYOTO UNIVERSITY · NIES JAPAN

# ផែនការអភិវឌ្ឍន៍បញ្ចេញកាបូនតិច

កម្ពុជាមានបំណងអភិវឌ្ឍប្រទេសរបស់ខ្លួនដោយផ្សារភ្ជាប់នូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ចីរភាពបរិស្ថាន និងការអភិរក្សវប្បធម៌ប្រកបដោយសុខដមនីយកម្ម សមហេតុផលនិងស្និទ្ធស្នាល។ ការអភិវឌ្ឍបញ្ចេញកាបូនតិចមិនគ្រាន់តែដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីផ្តោតលើការកែលម្អប្រសិទ្ធភាពថាមពល ដែលអាចបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សន្តិសុខថាមពល និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពបរិស្ថាន។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាការអភិវឌ្ឍបញ្ចេញកាបូនតិចគឺជាអភិក្រមគោលនយោបាយដ៏សំខាន់មួយមិនគ្រាន់តែដើម្បីដោះស្រាយបញ្ហាបរិស្ថានបណ្តាលមកពីការប្រែប្រួលអាកាសធាតុនោះទេប៉ុន្តែថែមទាំងដោះស្រាយបញ្ហាប្រឈមផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ អាស្រ័យហេតុនេះ ការបង្កើតគោលនយោបាយដើម្បីរៀបចំផែនការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមានតួនាទីយ៉ាងសំខាន់ដើម្បីតម្រែតម្រង់ទិសនិងជម្រុញអោយប្រទេសកម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍន៍ដោយចីរភាព ការអភិរក្សជីវចម្រុះ និងកិច្ចគាំពារបរិស្ថាន។ គោលនយោបាយចំនួន ៤ (បួន) និងយុទ្ធសាស្ត្រចំនួន ១២ (ដប់ពីរ) សម្រាប់ការអភិវឌ្ឍបញ្ចេញកាបូនតិចឆ្ពោះទៅរកឆ្នាំ២០៥០នៅកម្ពុជាត្រូវបានស្នើឡើង។ គោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះនឹងរួមចំណែកដោយផ្ទាល់ និងដោយប្រយោលដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ តាមរយៈការអនុវត្តនូវគោលនយោបាយនិងយុទ្ធសាស្ត្ររួមជាមួយសកម្មភាពមួយចំនួននោះ ប្រទេសកម្ពុជាអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ៣៨.០៣៩ និង ៨៧.៤៦២ kt$CO_2$eq./year នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ គោលនយោបាយស្តីពីសុខដមនីយកម្មរវាងសេដ្ឋកិច្ច សង្គម និងវប្បធម៌បៃតងអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់ ៣០% និង ៥៤% នៅឆ្នាំ ២០៣០ និង ២០៥០ រៀងៗខ្លួន។ បន្ទាប់មកគឺគោលនយោបាយស្តីពីបរិស្ថានបៃតងអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់ ៦៦% និង ៤០% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ គោលនយោបាយស្តីពីភូមិបៃតងអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានតិចជាងគេគឺ ៤% និង ៦% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ ចំណែកឯ គោលនយោបាយស្តីពី សេដ្ឋកិច្ចបៃតងរួមចំណែកដោយប្រយោល ប៉ុន្តែគោលនយោបាយនេះដើរតួនាទីយ៉ាងសំខាន់ដើម្បីសម្រេចបានគោលដៅកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប។

## គោលនយោបាយស្តីពីសុខដមនីយកម្មរវាងសេដ្ឋកិច្ច សង្គមនិងវប្បធម៌បៃតង

គោលនយោបាយនេះគ្របដណ្តប់លើយុទ្ធសាស្ត្រចំនួន ៦ (ប្រាំមួយ) រួមមាន៖ អភិបាលកិច្ចល្អនិងការអភិវឌ្ឍធនធានមនុស្សបៃតង ការគ្រប់គ្រងទេសចរណ៍បៃតង ការកៀរគរធនធានហិរញ្ញវត្ថុបៃតង ការអភិវឌ្ឍវិស័យថាមពលបៃតង ការអភិវឌ្ឍបច្ចេកវិទ្យានិងវិនិយោគទុនបៃតង និង ការអភិវឌ្ឍវិស័យដឹកជញ្ជូនបៃតង។ ការអនុវត្តគោលនយោបាយនេះអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ១១.៤០៩ (៣០%) និង ៤៧.២៤៦ kt$CO_2$eq./year (៥៤%) នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។

### អភិបាលកិច្ចល្អនិងការអភិវឌ្ឍធនធានមនុស្សបៃតង (កាត់បន្ថយដោយប្រយោល)

រាជរដ្ឋាភិបាលបានចាត់ទុកអភិបាលកិច្ចល្អថាជាស្នូលដើម្បីសម្រេចបានយុត្តិធម៌សង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌ និងចីរភាព។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាពខ្ពស់គឺជាតួបករណ៍ដ៏សំខាន់ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់ប្រទេស។ រាជរដ្ឋាភិបាលក៏បានចាត់ទុកយុវជនថាជាសសរទ្រូងរបស់ប្រទេសជាតិ ហើយក៏ជាឧត្តរាធិការីដ៏មានសក្តានុពល ដើម្បីថែរក្សាបាននូវសមិទ្ធិផលពីអតីតកាល និងដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនាពេលអនាគត។ ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។ យុទ្ធសាស្ត្រនេះរួមចំណែកដោយប្រយោល ដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែ វាដើរតួនាទីយ៉ាងសំខាន់ដើម្បីរួមចំណែកសម្រេចបានគោលដៅក្នុងការកាត់បន្ថយ។ សកម្មភាពសំខាន់ៗចំនួន ៥ (ប្រាំ) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី២។

**តារាងទី២៖** អភិបាលកិច្ចល្អនិងការអភិវឌ្ឍធនធានមនុស្សបៃតង

| ល. | សកម្មភាព |
|---|---|
| ១ | បញ្ជ្រាបទស្សនៈទានការអភិវឌ្ឍបៃតងទៅក្នុងកម្មវិធីសិក្សា |
| ២ | អនុវត្តនិងកែលម្អការគ្រប់គ្រងនិងការរៀបចំស្ថាប័នបៃតង |
| ៣ | អនុវត្តគំនិតផ្តួចផ្តើមការគ្រប់គ្រងបៃតងនិងការងារបៃតង |
| ៤ | ណែនាំនិងជម្រុញទស្សនៈទានបៃតងទៅដល់សហគមន៍មូលដ្ឋានសម្រាប់អនុវត្តន៍លើការគ្រប់គ្រងធនធានធម្មជាតិ |
| ៥ | ពង្រឹងនិងបង្កើនការអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់ទៅលើការចូលរួមរបស់យុវជននិងស្ត្រីសម្រាប់ការអភិវឌ្ឍសង្គមប្រកបដោយការបញ្ចេញកាបូនតិច |



**រូបភាពទី១៖** ការចូលរួមរបស់យុវជនក្នុងពេលយុទ្ធនាការថ្នាក់ជាតិស្តីពី ប្រទេសខ្ញុំគ្មានថង់ប្លាស្ទិក (ឯ.ឧ. ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាកំពុងថ្លែងសុន្ទរកថា)

### ការគ្រប់គ្រងទេសចរណ៍បៃតង (កាត់បន្ថយដោយប្រយោល)

វិស័យទេសចរណ៍ គឺជាវិស័យមួយដ៏សំខាន់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការបង្កើតការងារ ការបង្កើតប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ដើម្បីទាក់ទាញភ្ញៀវទេសចរ និងដោះស្រាយបញ្ហាបរិស្ថាន រាជរដ្ឋាភិបាលកំពុងរៀបចំផែនការដើម្បីអនុវត្តវិធានការដែលនាំទៅរកភាពបៃតង ស្អាត និងអនាម័យព្រមទាំងលើកទឹកចិត្តអោយមានការអនុវត្តការគ្រប់គ្រងសំណល់រឹងនិងរាវប្រកបដោយប្រសិទ្ធភាព។ ទេសចរណ៍បៃតងសម្រាប់ការសិក្សានេះសំដៅលើសកម្មភាពទាំងឡាយណាដែលរក្សាបានរឺធ្វើអោយមាននិរន្តរភាពការអភិវឌ្ឍនិងការគ្រប់គ្រងសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន។ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងរួមចំណែកដោយប្រយោលដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែវាមានតួនាទីសំខាន់ដើម្បីសម្រេចបានគោលដៅក្នុងការកាត់បន្ថយ។ សកម្មភាពសំខាន់ៗចំនួន ៥ (ប្រាំ) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៣។

**តារាងទី៣៖** ការគ្រប់គ្រងទេសចរណ៍បៃតង

| ល. | សកម្មភាព |
|---|---|
| ១ | ជម្រុញនិងអនុវត្តនូវទ្រឹស្តី ទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាល្អ |
| ២ | ជម្រុញការទាក់ទាញភ្ញៀវទេសចរតាមរយៈការផ្សព្វផ្សាយពីកេរ្តិ៍ដំណែលវប្បធម៌ជាតិ និង តំបន់ទេសចរណ៍ធម្មជាតិ (អេកូទេសចរណ៍) |
| ៣ | ជម្រុញការធ្វើទេសចរណ៍ជាក្រុមដោយប្រើប្រាស់នូវប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលមានលក្ខណៈងាយស្រួលនិងប្រកបដោយផាសុខភាព |
| ៤ | ជម្រុញអោយមានការប្រលងប្រណាំងទង់បៃតងនិងការផ្តល់រង្វាន់បៃតងសម្រាប់បណ្តាទីក្រុងនិងខេត្តដែលមានសក្តានុពលទេសចរណ៍ |
| ៥ | ណែនាំនិងលើកទឹកចិត្តអោយភ្ញៀវទេសចរប្រើប្រាស់សំណល់ឡើងវិញដើម្បីកាត់បន្ថយនិងគ្រប់គ្រងសំណល់ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ |



**រូបភាពទី១៖** ប្រាសាទព្រះវិហារជាបិតិកភ័ណ្ឌពិភពលោក

## ការកៀរគរធនធានហិរញ្ញវត្ថុបៃតង (កាត់បន្ថយដោយប្រយោល)

ប្រទេសកម្ពុជាបានអភិវឌ្ឍវិស័យហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលក៏បានដំណើរការជាសន្សឹមៗក្នុងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការថវិកាជាតិ តាមរយៈការបង្កើតក្របខណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុមួយ។ ក្រៅពីនេះ ប្រទេសកម្ពុជាបានប្រឹងប្រែងដើម្បីអាចទទួលបានមូលនិធិអាកាសធាតុបៃតងដោយផ្ទាល់ (Green Climate Fund) ដែលអាចក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់ការបង្កើតនូវហិរញ្ញប្បទានអាកាសធាតុ។ ការអនុវត្តយុទ្ធ-សាស្ត្រនេះនឹងរួមចំណែកដោយប្រយោលដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែ វាមានតួនាទីសំខាន់ដើម្បីសម្រេចបានគោលដៅក្នុងការកាត់បន្ថយ។ សកម្មភាពសំខាន់ៗចំនួន ៦ (ប្រាំមួយ) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៤។

**តារាងទី៤៖** ការកៀរគរធនធានហិរញ្ញវត្ថុបៃតង

| ល. | សកម្មភាព |
|---|---|
| ១ | អនុវត្តការលើកទឹកចិត្តផ្នែកហិរញ្ញប្បទានបៃតងសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ |
| ២ | អនុម័តនូវកំណែទម្រង់ថវិកាបៃតងសម្រាប់ការធ្វើវិនិយោគទុនបៃតង |
| ៣ | ណែនាំ និងអនុវត្តអភិក្រម Feed-In-Tariff សម្រាប់ការធ្វើវិនិយោគទុនលើវិស័យថាមពលកកើតឡើងវិញ |
| ៤ | អនុវត្តអភិក្រមការបង់ថ្លៃសេវាកម្មបរិស្ថាន (PES) ដោយផ្អែកលើគោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃ (Polluter Pays Principle) |
| ៥ | ធ្វើការកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍សម្រាប់សកម្មភាពនិងការអភិវឌ្ឍបៃតង (ឧ. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ) |
| ៦ | បង្កើតប្រព័ន្ធហិរញ្ញប្បទានផ្អែកលើទីផ្សារសមរម្យដើម្បីគាំទ្រដល់ការកៀរគរប្រភពធនធាន និង ការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព |

## ការអភិវឌ្ឍវិស័យថាមពលបៃតង

រាជរដ្ឋាភិបាលបានជម្រុញការកែលម្អប្រសិទ្ធភាពថាមពលដើម្បីកាត់បន្ថយតម្រូវការថាមពល និងបរិមាណបញ្ចេញឧស្ម័នកាបូនព្រមទាំងដើម្បីផ្តល់នូវសេវាថាមពលដែលអាចជឿជាក់បាន និងមានតម្លៃថោកសមរម្យប្រកបដោយនិរន្តរភាពបំផុត។ ការអនុវត្តយុទ្ធសាស្ត្រនេះមួយផ្នែកនឹងជួយអោយសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាល និង មួយផ្នែកទៀតរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ៤.២៨១ និង ១៦.៥៥៩ ktCO$_2$eq./year រឺ ប្រហែល ៣៨% និង ៣៥% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៣ (បី) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៥។

**តារាងទី៥៖** ការអភិវឌ្ឍវិស័យថាមពលបៃតង

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ជម្រុញអោយប្រើប្រាស់ថាមពលកកើតឡើងវិញតាមរយៈការសាងសង់រោងចក្រវារីអគ្គិសនី និងការដំឡើងថាមពលពន្លឺព្រះអាទិត្យ ខ្យល់ វារីអគ្គិសនីខ្នាតតូច ថាមពលទឹករលក និង ឡជីវឧស្ម័ន។ល។ | ២៥៣ | ១.២៨៤ |
| ២ | កែលម្អគុណភាពបណ្តាញចែកចាយអគ្គិសនីតាមរយៈការកាត់បន្ថយការបាត់បង់តាមបណ្តាញនិងការប្រើប្រាស់ដោយផ្ទាល់ | ៥៦០ | ១.៧២៦ |
| ៣ | ជម្រុញការប្រើប្រាស់ឧបករណ៍សន្សំសំចៃថាមពល និងប្រព័ន្ធគ្រប់គ្រងកម្លាំងអគ្គិសនីតាមផ្ទះ រួមទាំងការសន្សំសំចៃថាមពល ឧបករណ៍ប្រសិទ្ធភាពថាមពល ឧបករណ៍ត្រួតពិនិត្យភ្លើង និងជួសជុលឧបករណ៍អគ្គិសនី | ៣.៤៦៧ | ១៣.៥៤៨ |
| បរិមាណកាត់បន្ថយសរុប [ktCO$_2$eq./year] | | ៤.២៨១ | ១៦.៥៥៩ |



**រូបភាពទី៣៖** ការដំឡើងថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជា

## ការអភិវឌ្ឍបច្ចេកវិទ្យានិងវិនិយោគទុនបៃតង

រាជរដ្ឋាភិបាលបានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីកែលម្អបរិយាកាសធុរកិច្ចតាមរយៈការពង្រឹងក្របខណ្ឌគតិយុត្តិ ការជម្រុញបច្ចេកវិទ្យានិងនវានុវត្តភាព និងការបង្កើនការទទួលបានហិរញ្ញប្បទាន។ រាជរដ្ឋាភិបាលកំពុងជម្រុញបច្ចេកវិទ្យានិងវិនិយោគទុនបៃតងតាមរយៈការផ្តល់ការលើកទឹកចិត្ត ដល់អ្នកវិនិយោគទុន អោយធ្វើការវិនិយោគមូលធនរបស់ខ្លួន លើវិស័យកសិកម្ម ឧស្សាហកម្ម ដឹកជញ្ជូន ថាមពល និងសំណង់អាគារបៃតង។ល។ យុទ្ធសាស្ត្រនេះរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ១.៤៤៣ និង ៤.៩២៧ ktCO$_2$eq./year រឺ ប្រហែល ១៣% និង ១០% នៅឆ្នាំ ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៤ (បួន) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៦។

**តារាងទី៦៖** ការអភិវឌ្ឍបច្ចេកវិទ្យានិងវិនិយោគទុនបៃតង

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ជម្រុញឧស្សាហកម្មបៃតងនិងធ្វើអេកូតំបន់ឧស្សាហកម្ម | ៥៧២ | ១.៤៤០ |
| ២ | អនុវត្តការផ្ទេរបច្ចេកវិទ្យាបៃតងដូចជា៖ ផលិតកម្មស្អាត នវានុវត្តភាពផលិតផលប្រកបដោយនិរន្តរភាព និងការប្រើប្រាស់ថាមពលកកើតឡើងវិញ | ៨៧២ | ៣.៤៨៦ |
| ៣ | ជម្រុញការប្រកួតប្រជែងធុរកិច្ចបៃតង និងឥណទានបៃតង (ដោយប្រយោល) | | |
| ៤ | ជម្រុញនិងលើកទឹកចិត្តអោយធ្វើវិនិយោគទុនបៃតងក្នុងវិស័យកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ (ដោយប្រយោល) | | |
| បរិមាណកាត់បន្ថយសរុប [ktCO$_2$eq./year] | | ១.៤៤៣ | ៤.៩២៧ |

## ការអភិវឌ្ឍវិស័យដឹកជញ្ជូនបៃតង

ប្រទេសកម្ពុជាកំពុងទទួលរងនូវបញ្ហាប្រឈមជាច្រើនលើវិស័យដឹកជញ្ជូនដូចជា៖ ការកកស្ទះចរាចរណ៍ ប្រព័ន្ធដឹកជញ្ជូនសារធារណៈនៅមានកម្រិត និងការរំលោភច្បាប់ចរាចរណ៍ ។ល។ ការអនុវត្តយុទ្ធសាស្ត្រនេះរំពឹងថា វាមិនគ្រាន់តែដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះទេប៉ុន្តែក៏អាចជួយដោះស្រាយកង្វល់បញ្ហាចរាចរណ៍នានាផងដែរ។ យុទ្ធសាស្ត្រនេះនឹងរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានចំនួនហែល ៥.៦៨៥ និង ២៥.៧៦១ ktCO$_2$eq./year រឺ ប្រហែល ៥០% និង ៥៥% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៤ (បួន) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៧។

**តារាងទី៧៖** ការអភិវឌ្ឍវស័យដឹកជញ្ជូនបៃតង

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ជម្រុញអោយមានការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសាធារណៈ (ប្រព័ន្ធដឹកជញ្ជូនតំបន់ទីក្រុងប្រកបដោយប្រសិទ្ធភាពថាមពល) នៅតាមបណ្តាទីក្រុងធំៗមួយចំនួនដោយរៀបចំកន្លែងសម្រាប់ផ្លាស់ប្តូរ រឺ ឆ្លងកាត់ (Transit Facilities) | ១.៤៧០ | ២.៨៩៧ |
| ២ | នាំចូលនូវរថយន្តហាយប្រ៊ីត និងប្រើប្រាស់ម៉ាស៊ូតជីវៈ (Biodiesel) | ១០១ | ១.១១០ |
| ៣ | នាំចូល និងប្រើប្រាស់នូវរថយន្តបញ្ចេញឧស្ម័ន $CO_2$ តិច និង សន្សំសំចៃថាមពល | ២.៧១៤ | ១៥.៣៧៣ |
| ៤ | ផ្សព្វផ្សាយនិងអនុវត្តនូវ Eco-driving ដើម្បីសន្សំសំចៃថាមពល និងធ្វើការត្រួតពិនិត្យបច្ចេកទេសយានជំនិះជាប្រចាំ | ១.៤០០ | ៦.៣៨១ |
| បរិមាណកាត់បន្ថយសរុប [ktCO$_2$eq./year] | | ៥.៦៨៥ | ២៥.៧៦១ |



**រូបភាពទី៤៖** ការប្រើប្រាស់រថយន្តក្រុងសាធារណៈនៅទីក្រុងភ្នំពេញ

# គោលនយោបាយស្ដីពីបរិស្ថានបៃតង

គោលនយោបាយនេះគ្របដណ្តប់លើយុទ្ធសាស្ត្រចំនួន ៣ (បី) រួមមានៈ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព និង ការគ្រប់គ្រងកសិកម្មបៃតង។ ការអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាពអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានចំនួន ២៥.២១២ (៦៦%) និង ៣៥.៣១០ kt$CO_2$eq./year (៤០%) នៅឆ្នាំ ២០៣០ និង ២០៥០ រៀងៗខ្លួន។

## ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព

ព្រៃឈើផ្តល់នូវប្រភពធនធាន មុខងារនិងសេវាកម្មជាច្រើនដូចជា៖ ផលនិងអនុផលព្រៃឈើ រម្យនីយដ្ឋានសំរាកលំហែកាយ ជម្រកសត្វព្រៃ ការការពារប្រភពទឹកនិងដី ការផលិតឧស្ម័នអុកស៊ីសែន និងស្រូបយកឧស្ម័នពុល។ល។ រាជរដ្ឋាភិបាលបានប្តេជ្ញារក្សាគម្របព្រៃឈើអោយបាន៦០%។ ដូច្នេះ ការអនុវត្តយុទ្ធសាស្ត្រនេះមួយផ្នែកនឹងជួយអោយសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាល និងមួយផ្នែកទៀតរួមចំណែកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានចំនួនប្រហាក់ប្រហែលគ្នាគឺ ៨.៨៨៩kt$CO_2$eq./year រឺ ៣៥% និង ២៥% នៅឆ្នាំ ២០៣០ និង ២០៥០ រៀងៗខ្លួន។ វិធានការកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់អាចអនុវត្តបានក្នុងតម្លៃតិចជាង ៥០USD/t$CO_2$eq.។ សកម្មភាពសំខាន់ៗចំនួន ៥ (ប្រាំ) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៨។

**តារាង ៨៖** ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | អនុវត្តការគ្រប់គ្រងនិងការកែលម្អការកាប់បំផ្លាញព្រៃឈើ និង កាត់បន្ថយការកាប់ឈើខុសច្បាប់ | ៨.៨៦៦ | ៨.៨៦៦ |
| ២ | អនុវត្តកសិរុក្ខកម្មដែលអាចផ្តល់នូវផលិតផលកសិកម្មសម្រាប់ប្រើប្រាស់តាមលំនៅដ្ឋាន | ៩ | ៩ |
| ៣ | ជម្រុញការស្តារព្រៃឡើងវិញទាំងប្រភេទដុះលឿននិងយឺតរួមទាំងការដាំដុះឈើសម្រាប់ធ្វើពានិជ្ជកម្ម | ៨ | ៨ |
| ៤ | ជម្រុញការដាំដុះដើមឈើដោយផ្លាស់ប្តូររយៈពេលវែងនិងខ្លី | ៤ | ១ |
| ៥ | អនុវត្តច្បាប់ដើម្បីជៀសវាងការទន្រ្ទានដីព្រៃឈើដោយខុសច្បាប់ដើម្បីបង្កើនការដុះឡើងវិញតាមបែបធម្មជាតិ | ១ | ១ |
| បរិមាណកាត់បន្ថយសរុប [kt$CO_2$eq./year] | | ៨.៨៨៩ | ៨.៨៨៦ |

## ការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព

កំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច នគរូបនីយកម្មយ៉ាងឆាប់រហ័ស និងការអភិវឌ្ឍឧស្សាហ៍កម្មគឺជាមូលហេតុចំបងក្នុងការបង្កើតសំណល់នៅក្នុងប្រទេសកម្ពុជា។ ការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព មិនគ្រាន់តែដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាបាននូវការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពនិងត្រឹមត្រូវ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច តាមរយៈការធ្វើជីកំប៉ុស្តិ៍ និងការកែច្នៃសំណល់ ។ល។ យុទ្ធសាស្ត្រនេះនឹងអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ៧៥១ និង ៥.៨៧៤ kt$CO_2$eq./year រឺប្រហែល ២% និង ៧% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៧ (ប្រាំពីរ) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី៩។

**តារាង ៩៖** ការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | រៀបចំទីលានចោលសំរាមប្រកបដោយប្រសិទ្ធភាពបរិស្ថានតាមរយៈការរៀបចំយុទ្ធសាស្ត្រនិងផែការគ្រប់គ្រងសំណល់ ការប្រមូលសំណល់ និងការបែងចែកសំណល់តាមប្រភេទ | ១៩៦ | ១.១០៧ |
| ២ | កាត់បន្ថយការបង្កើតសំណល់និងពង្រីកការប្រើប្រាស់ធនធានកកើតឡើងវិញដោយអនុវត្តន៍គោលការណ៍ ៣Rs | ៤១២ | ៣.៨១៤ |
| ៣ | អនុវត្តបច្ចេកវិទ្យាបំលែងពីសំណល់ទៅជាអគ្គិសនី (ការដុតសំណល់ និងការបង្កើតជាអគ្គិសនី) (incineration) | ២៩ | ៤១ |
| ៤ | អនុវត្តការបង្កើតជីកំប៉ុស្តិ៍ពីសំណល់ | ៩៨ | ១០៦ |
| ៥ | ដំឡើងរោងចក្រប្រព្រឹត្តិកម្មសំណល់រាវ | ១៦ | ៨០៦ |
| ៦ | អនុវត្តការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពបរិស្ថានតាមរយៈ ការរៀបចំកន្លែងបោះចោលនិងរក្សាទុកសំណល់ និង ការត្រួតពិនិត្យជាប្រចាំនៅការនាំចូលទំនិញជជុះ (ដោយប្រយោល) | | |
| ៧ | ជម្រុញអោយមានការគ្រប់គ្រងនិងដឹកនាំដោយផ្ទាល់នូវថ្នាក់មូលដ្ឋានដើម្បីសម្រួលដល់ការគ្រប់គ្រងសំណល់តាមបែបវិមជ្ឈការ (ដោយប្រយោល) | | |
| បរិមាណកាត់បន្ថយសរុប [kt$CO_2$eq./year] | | ៧៥១ | ៥.៨៧៤ |

## ការគ្រប់គ្រងកសិកម្មបៃតង

កំណើនសេដ្ឋកិច្ចជាប្រចាំនិងមានស្ថេរភាពពឹងផ្អែកមួយផ្នែកធំលើការអភិវឌ្ឍដ៏ល្អនៃវិស័យកសិកម្ម។ ក្រៅពីនេះ រាជរដ្ឋាភិបាលកំពុងជម្រុញការនាំចេញអង្កអោយបានយ៉ាងតិច ១ (មួយ) លានតោនត្រឹមឆ្នាំ២០១៥។ រាជរដ្ឋាភិបាលក៏បានបង្កើនផលិតភាពសាច់ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ។ អាស្រ័យហេតុនេះ ការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព មិនគ្រាន់តែជួយអោយសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានចំនួន ១៥.៥៧២ និង ២០.៥៥០ kt$CO_2$eq./year រឺ ប្រហែល ៦២% និង ៥៨% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៩ (ប្រាំបួន) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី១០។

**តារាង ១០៖** ការគ្រប់គ្រងកសិកម្មបៃតង

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ការអនុវត្តការផ្លាស់ប្តូរទឹកស្រែពាក់កណ្តាលរដូវដែលពាក់ព័ន្ធទៅនឹងការបង្ហូរទឹកចេញពីស្រែ | ៨.៥៩៥ | ១០.៦៩៩ |
| ២ | ការអនុវត្តនូវការកាប់ចិញ្ច្រាំគល់ជញ្ជ្រាំងស្រូវក្រោយការប្រមូលផលស្រូវនៅក្នុងស្រែដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន $CH_4$ | ២.៦៨៣ | ៣.៣៣៩ |
| ៣ | ជម្រុញអោយជំនួសការប្រើប្រាស់ជី Urea ដោយប្រើជី Ammonium Sulfate ដើម្បីកាត់បន្ថយផលិតភាព $CH_4$ | ១.៤៨៣ | ១.៨៤៦ |
| ៤ | ជម្រុញការប្រើប្រាស់ជីប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលតម្រូវអោយដាក់ជីអាសូត(N)ចំនួន៣ (បី) ដងក្នុងអំឡុងពេលដំណាំស្រូបយកជីរជាតិ | ១.២២៧ | ១.៨១៤ |
| ៥ | ផ្លាស់ប្តូរពីការភ្ជួរដីដោយមិនបាច់ភ្ជួរវិញដែលធ្វើនៅកន្លែងដីដែលត្រូវបានរំខាន និងមានកាកសំណល់ដំណាំ | ២៤ | ៤៨ |
| ៦ | ផ្តល់ប្រភពចំណីសត្វគោក្របីដែលមានគុណភាពល្អដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័ន $CH_4$ ពីសត្វទាំងនោះ និងដើម្បីបង្កើនផលិតភាពសត្វ | ៧៦៦ | ១.៣៧៩ |
| ៧ | នាំចូលនូវប្រភេទពូជសត្វដែលមានគុណភាពខ្ពស់តាមរយៈការកែលម្អពូជគោចិញ្ចឹមយកទឹកដោះ | ៥២១ | ៩៣៨ |
| ៨ | ជម្រុញអោយដាក់ជីលាមកសត្វជារៀងរាល់ថ្ងៃ ជាពិសេសកន្លែងដែលជីទាំងនោះត្រូវបានយកចេញពីរណ្តៅជាប្រចាំ ហើយត្រូវស្រោចស្រពទៅលើដំណាំក្នុងរយៈពេល២៤ម៉ោង | ២១៣ | ៣៨១ |
| ៩ | សាងសង់ឡជីវឧស្ម័នដើម្បីផលិតហ្គាសសម្រាប់ចំអិនអាហារនិងភ្លើង ចំណែកឯកាកសំណល់ប្រើប្រាស់ជាជីសរីរាង្គសម្រាប់ដំណាំ | ៦០ | ១០៦ |
| បរិមាណកាត់បន្ថយសរុប [kt$CO_2$eq./year] | | ១៥.៥៧២ | ២០.៥៥០ |



**រូបភាពទី៥៖** ការសាងសង់ឡជីវឧស្ម័នដើម្បីផលិតហ្គាសសម្រាប់ចំអិនអាហារ និងភ្លើងបំភ្លឺ ចំណែកឯកាកសំណល់ប្រើប្រាស់ជាជីសម្រាប់ការធ្វើកសិកម្ម

## គោលនយោបាយស្ដីពីភូមិបៃតង

គោលនយោបាយនេះគ្របដណ្ដប់លើយុទ្ធសាស្ត្រចំនួន ២ (ពីរ) រួមមាន៖ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយការបញ្ចេញកាបូនតិច និងការកសាងសំណង់អាគារបៃតង។ ការអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាពអាចកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានចំនួនប្រហែល ១.៤១៧ (៤%) និង ៤.៩០៧ ktCO$_2$eq./year (៥%) នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។

### ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយការបញ្ចេញកាបូនតិច

រាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងដើម្បីសម្រួលដល់ការកកស្ទះចរាចរណ៍និងកង្វល់គ្រោះថ្នាក់ចរាចរណ៍តាមផ្លូវគោក។ល។ វិធានការភាគច្រើនផ្ដោតលើការផ្លាស់ប្ដូរមធ្យោបាយធ្វើដំណើរ (Modal Shift) និងការរៀបចំទីក្រុងអោយកាន់តែតូចនៅតាមបណ្ដាទីក្រុងមួយចំនួន។ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងអាចរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ១.០៨៤ និង ៣.៦១៨ ktCO$_2$eq./year រឺ ប្រហែល ៧៦% និង ៧៤% នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៣ (បី) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី១១។

**តារាង ១១៖** ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយការបញ្ចេញកាបូនតិច

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ប្រើប្រាស់នូវរថភ្លើងដឹកទំនិញសម្រាប់ការដឹកជញ្ជូនចម្ងាយឆ្ងាយ | ៣៨៤ | ៤២៧ |
| ២ | រៀបចំផ្លូវដើរប្រកបសុវត្ថិភាព និង ងាយស្រួលដើម្បីបង្កើតជាទីក្រុងសម្រាប់អ្នកធ្វើដំណើរដោយថ្មើរជើង | ៧០០ | ៣.១៩១ |
| ៣ | រៀបចំផ្លូវថ្នល់តាមស្តង់ដា ដោយបែងចែកអោយដាច់ពីគ្នារវាងផ្លូវឡាន ម៉ូតូ កង់ និងថ្មើរជើង ដើម្បីជៀសវាងគ្រោះថ្នាក់ និងការកកស្ទះចរាចរណ៍ (ដោយប្រយោល) | | |
| បរិមាណកាត់បន្ថយសរុប [ktCO$_2$eq./year] | | ១.០៨៤ | ៣.៦១៨ |

### ការកសាងសំណង់អាគារបៃតង

ការកសាងសំណង់អាគារបៃតងសំដៅលើការអនុវត្តនូវវិធីសាស្ត្រមួយចំនួនដូចជា៖ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ការសន្សំសំចៃថាមពលនិងប្រសិទ្ធភាពថាមពល និងការសន្សំសំចៃការប្រើប្រាស់ទឹក។ល។ ប្រការនេះរួមចំណែកយ៉ាងច្រើនដើម្បីលើកកម្ពស់សុខមាលភាព ការរស់នៅ និងផលិតភាព។ ការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាពនឹងអាចរួមចំណែកកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់បាន ៣៣៣ និង ១.២៨៩ ktCO$_2$eq./year រឺប្រហែល ២៤% និង ២៦% នៅឆ្នាំ ២០៣០ និង ២០៥០ រៀងៗខ្លួន។ សកម្មភាពសំខាន់ៗចំនួន ៩ (ប្រាំបួន) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី១២។

**តារាង ១២៖** ការកសាងសំណង់អាគារបៃតង

| ល. | សកម្មភាព | ២០៣០ | ២០៥០ |
|---|---|---|---|
| ១ | ជម្រុញអោយគ្រប់ផ្ទះនិងស្ថាប័នទាំងអស់សន្សំសំចៃថាមពល | ១៥៥ | ៦២៥ |
| ២ | ផ្សព្វផ្សាយនិងអនុវត្តការរៀបចំនិងកសាងអាគារបៃតងតាមរយៈការប្រើប្រាស់សម្ភារៈប្រសិទ្ធភាពថាមពល | ៧៦ | ២៦៨ |
| ៣ | បង្កប់នូវឧបករណ៍ប្រើប្រាស់ថាមពលកកើតឡើងវិញ និងឧបករណ៍សន្សំសំចៃថាមពលនៅពេលរៀបចំផែនការសង់សំណង់អាគារផ្សេងៗ | ១០២ | ៣៩៦ |
| បរិមាណកាត់បន្ថយសរុប [ktCO$_2$eq./year] | | ៣៣៣ | ១.២៨៩ |

## គោលនយោបាយស្ដីពីសេដ្ឋកិច្ចខៀវ (កាត់បន្ថយដោយប្រយោល)

គោលនយោបាយនេះរួមចំណែកដោយប្រយោលដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែ វាដើរតួនាទីយ៉ាងសំខាន់ដើម្បីរួមចំណែកសម្រេចបានគោលដៅក្នុងការកាត់បន្ថយ។ គោលនយោបាយនេះមានតែយុទ្ធសាស្ត្រស្ដីពី ជំនួញនាវាសមុទ្របៃតងនិងការគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយចីរភាពមួយប៉ុណ្ណោះ។

### ជំនួញនាវាសមុទ្របៃតងនិងការគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយចីរភាព

ឆ្នេរសមុទ្រកម្ពុជាគឺជាតំបន់ទេសចរណ៍ដ៏ស្រស់ស្អាតមួយដែលបានជាប់ចំណាត់ថ្នាក់ជាឆ្នេរស្អាតបំផុតលើសកលលោកក្នុងឆ្នាំ២០១១។ ក្រៅពីប្រព័ន្ធអេកូស៊ីស្ទែមសមុទ្រ នៅមានធនធានប្រេងនិងរ៉ែសំខាន់ៗផ្សេងៗមួយចំនួនទៀតនៅបាតសមុទ្រ។ រាជរដ្ឋាភិបាលមានបំណងថែរក្សាប្រព័ន្ធអេកូស៊ីស្ទែមអោយមានសុខភាពល្អតាមរយៈការអនុវត្តអភិក្រមផ្អែកលើភាពជាដៃគូរ ផ្អែកលើប្រជាជន គោលនយោបាយពាក់ព័ន្ធនានា និងតាមបែបវិនិយោគទុនដែលទាមទារអោយអនុវត្ត និងពង្រឹងចំណេះដឹង សមត្ថភាពសហគមន៍និងអ្នកពាក់ព័ន្ធផ្សេងៗ ពង្រឹងអភិបាលកិច្ច រក្សាលំនឹងកម្រិតជីវភាពរស់នៅ និងបង្កើនភាពធន់នឹងហានិភ័យអាកាសធាតុ និង ការប្រែប្រួលអាកាសធាតុ។ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងរួមចំណែកដោយប្រយោលដើម្បីកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ចំណែកឯ ការកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈការអភិរក្ស និងដាំដើមកោងកាងឡើងវិញត្រូវបានគណនានៅក្នុងយុទ្ធសាស្ត្រ ស្ដីពី ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។ សកម្មភាពសំខាន់ៗចំនួន ៨ (ប្រាំបី) បានស្នើឡើងដូចមានបង្ហាញនូវក្នុងតារាងទី១៣។

**តារាង ១៣៖** ជំនួញនាវាសមុទ្របៃតងនិងការគ្រប់គ្រងតំបន់ឆ្នេរប្រកបដោយចីរភាព

| ល. | សកម្មភាព |
|---|---|
| ១ | អនុវត្តនូវស្តង់ដាការបញ្ចេញឧស្ម័ននៅក្នុងវិស័យដឹកជញ្ជូនតាមសមុទ្រតាមរយៈការធ្វើអធិការកិច្ច និង ការបំពាក់ប្រព័ន្ធជួសជុលថែរក្សាជាប្រចាំ |
| ២ | ជម្រុញអោយមានការអនុវត្តការគ្រប់គ្រងតំបន់ឆ្នេរដោយមានការចូលរួម និងការដាំដើមកោងកាងឡើងវិញ |
| ៣ | បង្កើត និងជម្រុញការគ្រប់គ្រង Ballast Water ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យការជ្រៀតចូលប្រភេទសត្វចង្រៃ |
| ៤ | ធ្វើការរុករក ស្រាវជ្រាវ និង ធ្វើអាជីវកម្មធនធានប្រេងអោយបានសមរម្យ និង រៀបចំនូវគោលនយោបាយ និងបទដ្ឋានគតិយុត្តិសម្រាប់ការគ្រប់គ្រងការកំពប់ប្រេង |
| ៥ | រៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់សមុទ្រតំបន់អាស៊ីបូព៌ា |
| ៦ | ជម្រុញនូវការគ្រប់គ្រងនិងអភិរក្សជីវចម្រុះសមុទ្រដូចជា៖ ព្រៃកោងកាង ផ្កាសមុទ្រ និងស្មៅសមុទ្រ។ល។ |
| ៧ | ធ្វើការសិក្សាវាយតម្លៃការហូរច្រោះតំបន់ឆ្នេរអោយបានស៊ីជម្រៅនិងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងការហូរច្រោះតំបន់ឆ្នេរទាំងនោះ |
| ៨ | រៀបចំ និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការបំពុលសមុទ្រពីដីគោក |



**រូបភាពទី៦៖** ការអភិរក្សនិងកិច្ចការពារព្រៃកោងកាង



**រូបភាពទី៧៖** ការយុទ្ធនាការថ្នាក់ជាតិដើម្បីដាំដើមកោងកាងឡើងវិញ

# ការព្យាករណ៍បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្ដានុពលកាត់បន្ថយតាមវិស័យនីមួយៗ

តាមការព្យាករណ៍បង្ហាញថាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជានឹងកើនឡើងពី ៤.៨៤៧kt$CO_2$eq./year (គីឡូតោននៃសមមូលកាបូនក្នុងមួយឆ្នាំ) រហូតដល់ ២០.២៤៥ (៤ដង) និង ១២០.៥២៣ kt$CO_2$eq./year (២៥ ដង) នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ប៉ុន្តែ ការព្យាករណ៍ដដែលបង្ហាញថា បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងថយចុះមកត្រឹម -១៧.៧៩៤ និង ៣៣.០៥៧ kt$CO_2$eq./year នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួន។ តាមលទ្ធផលបង្ហាញថា បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបចំនួនប្រហែល ៣៨.០៣៩ និង ៨៧.៤៦២ kt$CO_2$eq./year នឹងអាចកាត់បន្ថយបាននៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ ចំណែកឯ បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់សំរាប់មនុស្សម្នាក់ៗនឹងកើនឡើងពី ០,៤t$CO_2$eq./year នៅឆ្នាំ២០១០ រហូតដល់ ១,១ និង ៥,៥ t$CO_2$eq./year នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន ប៉ុន្តែ បរិមាណនេះនឹងថយចុះមកត្រឹម -១,០ និង១,៥ t$CO_2$eq./year នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។

## វិស័យថាមពល

ការសិក្សានេះប្រើប្រាស់គំរូ ExSS ដើម្បីគណនាតម្រូវការថាមពល បរិមាណបញ្ចេញឧស្ម័នកាបូននិងសក្ដានុពលកាត់បន្ថយ។ គំរូនេះគឺជាប្រព័ន្ធសមីការដែលអាចប្រើដើម្បីគណនាសន្ទស្សន៍ម៉ាក្រូសេដ្ឋកិច្ចសង្គមនិងបញ្ហាបរិស្ថាន។

### តម្រូវការប្រភពថាមពល៖

ដោយសារកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ចចេះតែកើនឡើងៗដូចដែលបង្ហាញនូវក្នុងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនោះ តាមការព្យាករណ៍បង្ហាញថា តម្រូវការប្រភពផ្គត់ថាមពលនឹងកើនឡើងពី ៤.៥៨៧ktoe/year (គីឡូតោននៃសមមូលប្រេងឥន្ទនៈក្នុងមួយឆ្នាំ) នៅក្នុងឆ្នាំ២០១០ រហូតដល់ ១៩.៣២៧(៤ដង) និង ៧០.៥៩៨ ktoe/year (១៥ដង) ក្នុងឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ប៉ុន្តែ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួន តម្រូវការប្រភពផ្គត់ថាមពលនឹងថយចុះមកត្រឹម ៨.៤៩៩ (២ដង) និង ២៨.៥១៥ ktoe/year (៦ដង) នៅឆ្នាំ2030CM and 2050CM រៀងៗខ្លួន។ ប្រហែល ៥៦% និង ៦០% នៃបរិមាណតម្រូវការប្រភពថាមពលសរុបរំពឹងថាអាចកាត់បន្ថយបាននៅក្នុងឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ តារាងទី១៤ បង្ហាញពីតម្រូវការប្រភពផ្គត់ថាមពលតាមប្រភេទឥន្ទនៈនីមួយៗ (ktoe/year)។

**តារាង ១៤៖** តម្រូវការប្រភពថាមពលតាមប្រភេទឥន្ទនៈ (ktoe/year)

| ប្រេងឥន្ទនៈ/ឆ្នាំ [ktoe/year] | 2010 | 2030BaU | 2030CM | 2050BaU | 2050CM |
|---|---|---|---|---|---|
| ធ្យូងថ្ម | ៨ | ៤៤០ | ១៤២ | ១.៦៩៣ | ៣៦៨ |
| ផលិតផលប្រេង | ១.៣៥១ | ៦.២១០ | ២.៩០៥ | ២៤.៤៦៤ | ១១.៤២៩ |
| ឧស្ម័នធម្មជាតិ | 0 | ៩៧០ | ៣៧៤ | ៣.៧២៩ | ៩៦៨ |
| ថាមពលវារីអគ្គិសនី | ២ | ៣៩០ | ១៧០ | ១.៥០១ | ៤៤០ |
| ថាមពលពន្លឺព្រះអាទិត្យ/ខ្យល់ | 0 | ១១ | ២៤ | ៤៣ | ៦៣ |
| ថាមពលជីវម៉ាស់/សំណល់ | ៣.១០៩ | ១១.២៤១ | ៤.៨៥៤ | ៣៨.៩១៨ | ១៥.១៧៣ |
| ការនាំចូល | ១១៧ | ៦៥ | ២៨ | ២៥១ | ៧៤ |
| ការផ្គត់ប្រភពថាមពលសរុប | ៤.៥៨៧ | ១៩.៣២៧ | ៨.៤៩៩ | ៧០.៥៩៨ | ២៨.៥១៥ |

### តម្រូវការថាមពល៖

តាមការព្យាករណ៍បង្ហាញថាតម្រូវការថាមពលនឹងកើនឡើងពី ៤.៣៨៦ktoe/year នៅក្នុងឆ្នាំ២០១០ រហូតដល់ ១៨.៣៧៤ (៥ដង) និង ៦៦.៩៣២ ktoe/year (១៥ដង) ក្នុងឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួននោះ តម្រូវការថាមពលនឹងថយចុះមកត្រឹម ៨.១៨០ (២ដង) និង ២៧.៦៩១ ktoe/year (៦ដង) នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ ប្រហែល ៥៥% និង ៥៩% នៃបរិមាណតម្រូវការថាមពលសរុបរំពឹងថាអាចកាត់បន្ថយបាននៅក្នុងឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ តម្រូវការថាមពលសម្រាប់មនុស្សម្នាក់ៗរំពឹងថានឹងកើនឡើងពី ៣១៤kgoe/year នៅក្នុងឆ្នាំ២០១០រហូតដល់ ៩៩៩ និង ៣.០៤៧ kgoe/year ក្នុងឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ប៉ុន្តែគេរំពឹងថានឹងថយចុះមកត្រឹម ៤៤៥ និង ១.២៦១ kgoe/year នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ តារាងទី១៥ បង្ហាញពីតម្រូវការថាមពលតាមវិស័យនីមួយៗ (ktoe/year)។

**តារាង ១៥៖** តម្រូវការថាមពលតាមវិស័យ (ktoe/year)

| តាមវិស័យ/ឆ្នាំ [ktoe/year] | 2010 | 2030BaU | 2030CM | 2050BaU | 2050CM |
|---|---|---|---|---|---|
| លំនៅដ្ឋាន | ២.៥៤៩ | ៧.៣៩៦ | ២.៤០៩ | ២៥.៩៩៧ | ៦.៦៩០ |
| មណ្ឌលពានិជ្ជកម្ម | ១៧២ | ១.១០៧ | ៦៧២ | ៣.០៨៦ | ១.៥៦០ |
| ឧស្សាហ៍កម្ម | ១.០២១ | ៦.១០០ | ៣.៤៥៣ | ២០.៨៦៨ | ១១.៤៩៧ |
| ដឹកជញ្ជូនអ្នកដំណើរ | ៣២១ | ២.០០៥ | ៨៧៩ | ៧.០០៦ | ៣.០២៧ |
| ដឹកជញ្ជូនទំនិញ | ៣២៤ | ១.៧៦៥ | ៧៦៨ | ៩.៩៧៥ | ៤.៩១៧ |
| បរិមាណតម្រូវការថាមពលសរុប | ៤.៣៨៦ | ១៨.៣៧៤ | ៨.១៨០ | ៦៦.៩៣២ | ២៧.៦៩១ |
| សម្រាប់មនុស្សម្នាក់ៗ (kgoe/person) | ៣១៤ | ៩៩៩ | ៤៤៥ | ៣.០៤៧ | ១.២៦១ |

### បរិមាណបញ្ចេញឧស្ម័ននិងសក្ដានុពលកាត់បន្ថយ៖

ដោយសារកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ចនិងតម្រូវការថាមពលចេះតែកើនឡើងៗនោះ តាមការព្យាករណ៍បង្ហាញថា ការបញ្ចេញឧស្ម័នកាបូននឹងកើនឡើងពី ៤.២២១ kt$CO_2$/year នៅក្នុងឆ្នាំ២០១០ រហូតដល់ ២៣.២៧៧ (៦ដង) និង ៩១.៣២៥ kt$CO_2$/year (២២ដង) ក្នុងឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួន បរិមាណបញ្ចេញឧស្ម័នកាបូននឹងថយចុះមកត្រឹម ១០.៤៥១ (៣ដង) និង ៣៩.១៧២ kt$CO_2$/year (៩ដង) នៅឆ្នាំ2030CM and 2050CM រៀងៗខ្លួន។ ប្រហែល ៥៥% និង ៥៧% នៃបរិមាណបញ្ចេញឧស្ម័នកាបូនសរុបរំពឹងថាអាចកាត់បន្ថយបាននៅក្នុងឆ្នាំ 2030CM និង 2050CM រៀងៗខ្លួន។ បរិមាណបញ្ចេញឧស្ម័នកាបូនសម្រាប់មនុស្សម្នាក់ៗរំពឹងថានឹងកើនឡើងពី 0,៣t$CO_2$/year នៅក្នុងឆ្នាំ២០១០ រហូតដល់ ១,៣ និង ៤,២ t$CO_2$/year ក្នុងឆ្នាំ 2030BaU និង 2050BaU រៀងៗខ្លួន។ ប៉ុន្តែគេរំពឹងថានឹងថយចុះមកត្រឹម 0,៦ និង ១,៨ t$CO_2$/year នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ តារាងទី១៦ និង ក្រាហ្វិកទី១ បង្ហាញពីបរិមាណបញ្ចេញឧស្ម័នកាបូននិងសក្ដានុពលកាត់បន្ថយ (kt$CO_2$/year)។

**តារាងទី១៦៖** បរិមាណបញ្ចេញឧស្ម័នកាបូននិងសក្ដានុពលកាត់បន្ថយ (kt$CO_2$/year)

| ឧស្ម័នកាបូន/ឆ្នាំ [kt$CO_2$/year] | 2010 | 2030BaU | 2030CM | 2050BaU | 2050CM |
|---|---|---|---|---|---|
| លំនៅដ្ឋាន | ៨៣០ | ២.៤១៤ | ៩១៨ | ៩.៨៨៩ | ២.០៣៤ |
| មណ្ឌលពានិជ្ជកម្ម | ២១៧ | ១.៤៣៣ | ៤៨២ | ៣.៦៦៣ | ១.២៩៨ |
| ឧស្សាហ៍កម្ម | ១.១៧៣ | ៧.៥៣៦ | ៣.៩២៦ | ២៣.៦៩១ | ១១.១៣៦ |
| ដឹកជញ្ជូនអ្នកដំណើរ | ៩៩៦ | ៦.៣៧៤ | ២.៧៤៣ | ២២.២៧៦ | ៩.៤៣១ |
| ដឹកជញ្ជូនទំនិញ | ១.០០៤ | ៥.៥២១ | ២.៣៨៣ | ៣១.៨០៦ | ១៥.២៧៣ |
| បរិមាណបញ្ចេញនិងកាត់បន្ថយសរុប | ៤.២២១ | ២៣.២៧៧ | ១០.៤៥១ | ៩១.៣២៥ | ៣៩.១៧២ |
| សម្រាប់មនុស្សម្នាក់ៗ (t$CO_2$/(person.year)) | ០,៣ | ១,២៧ | ០,៥៧ | ៤,១៦ | ១,៧៨ |




**ក្រាហ្វិកទី១៖** បរិមាណបញ្ចេញឧស្ម័នកាបូននិងសក្ដានុពលកាត់បន្ថយ (kt$CO_2$/year)

# វិស័យកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗ (AFOLU)

ដើម្បីគណនាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយពីវិស័យកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗ (AFOLU) ការសិក្សានេះប្រើប្រាស់គំរូ AFOLU-B។ វាគឺជាប្រភេទគណនាពីក្រោមឡើងលើ (bottom-up) ហើយ បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយគណនាដោយប្រើមុខងារនៃតម្លៃកាត់បន្ថយ (Abatement Costs) ដែលជាប៉ារ៉ាម៉ែត្រតំណាងអោយធនធានកាត់បន្ថយបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយអនុលោមតាមអញ្ញតិមួយចំនួនសម្រាប់តម្លៃនិងវិធានការកាត់បន្ថយ។ លទ្ធផលនៃបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង សក្តានុពលកាត់បន្ថយមានបង្ហាញដូចខាងក្រោម៖

## បរិមាណបញ្ចេញឧស្ម័ននិងសក្តានុពលកាត់បន្ថយ៖

តាមលទ្ធផលនៃការសិក្សាបង្ហាញថាវិស័យ AFOLU គឺជាអាងស្រូបកាបូន ហើយសមត្ថភាពស្រូបកាបូននឹងកើនឡើងពី ៩៤០ រហូតដល់ ៨.៧៦៤ $ktCO_2eq./year$ នៅឆ្នាំ ២០១០ និង 2030BaU រៀងៗខ្លួន។ ប៉ុន្តែ វិស័យនេះនឹងបញ្ចេញឧស្ម័នផ្ទះកញ្ចក់រហូតដល់ ១៣.៩៨២ $ktCO_2eq./year$ នៅឆ្នាំ2050BaU។ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួន សមត្ថភាពស្រូបកាបូននឹងកើនឡើងបន្ថែមទៀតពី ៣៣.២២៤ និង ១៥.៤៥៦ $ktCO_2eq./year$ នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ ចំពោះវិស័យកសិកម្ម បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងកើនឡើងពី ២៦.១៤២ $ktCO_2eq./year$ នៅឆ្នាំ២០១០ រហូតដល់ ៤៤.០៦២ (២ដង) និង ៦៦.៨០៨ $ktCO_2eq./year$ (៣ដង) នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។ ប៉ុន្តែ បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងថយចុះមកត្រឹម ២៨.៤៩០ និង ៤៦.២៥៩ $ktCO_2eq./year$ នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ វិធានការកាត់បន្ថយអាចអនុវត្តបាននូវតម្លៃតិចជាង ១០USD/$tCO_2eq.$។ ចំពោះវិស័យការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើគឺជាអាងស្រូបកាបូន ហើយសមត្ថភាពស្រូបកាបូននឹងកើនឡើងពី ២៧.០៨២ $ktCO_2eq./year$ នៅឆ្នាំ២០១០ រហូតដល់ចំនួនប្រហាក់ប្រហែលគ្នាគឺ ៥២.៨២៦ $ktCO_2eq./year$ ទាំងនៅឆ្នាំ2030BaU និង 2050BaU។ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួន សមត្ថភាពស្រូបកាបូននឹងកើនឡើងបន្ថែមទៀតរហូតដល់ចំនួនប្រហាក់ប្រហែលគ្នាគឺ ៦១.៧១៥$ktCO_2eq./year$ ទាំងនៅឆ្នាំ2030CM និង 2050CM។ វិធានការកាត់បន្ថយអាចអនុវត្តបាននូវតម្លៃតិចជាង ៥០USD/$tCO_2eq.$។ តារាងទី១៧ បង្ហាញពីបរិមាណបញ្ចេញនិងសក្តានុពលកាត់បន្ថយ ($ktCO_2eq./year$)

**តារាងទី១៧៖** បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយ ($ktCO_2eq./year$)

| តាមវិស័យ/ឆ្នាំ [$ktCO_2eq./year$] | 2010 | 2030BaU | 2030CM | 2050BaU | 2050CM |
|---|---|---|---|---|---|
| វិស័យកសិកម្ម | | | | | |
| ការទំពាអៀង | ៤.៣២៦ | ៦.០១៥ | ៤.៧២៨ | ១០.៨២៦ | ៨.៥០៩ |
| ការគ្រប់គ្រងលាមកសត្វ | ៦០៦ | ៩៩៣ | ៧២១ | ១.៥៦៨ | ១.០៨១ |
| ការដាំដុះដំណាំ | ១៧.០៩០ | ២៦.៤៧៩ | ១៣.៦៩៥ | ៣២.៩៦១ | ១៧.០៥៩ |
| ការគ្រប់គ្រងដី | ៤.១២០ | ១០.៥៧៤ | ៩.៣៤៨ | ២១.៤៥៤ | ១៩.៦០៩ |
| សរុប | ២៦.១៤២ | ៤៤.០៦២ | ២៨.៤៩០ | ៦៦.៨០៨ | ៤៦.២៥៩ |
| វិស័យការប្រើប្រាស់ដី ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ * | | | | | |
| ការប្រែប្រួលគម្របព្រៃឈើ និងសមត្ថភាពស្តុកជីវម៉ាស់របស់ឈើផ្សេងៗទៀត | -៤៦.០១៥ | -៤៥.៦៩១ | -៥៤.៥៥៩ | -៤៥.៦៩១ | -៥៤.៥៥៩ |
| ការប្រែប្រួលគ្របព្រៃឈើ និងវាលស្មៅ | ១៨.៩៣៣ | -៧.១៣៥ | -៧.១៥៦ | -៧.១៣៥ | -៧.១៥៦ |
| សរុប | -២៧.០៨២ | -៥២.៨២៦ | -៦១.៧១៥ | -៥២.៨២៦ | -៦១.៧១៥ |
| បរិមាណបញ្ចេញនិងកាត់បន្ថយសរុប | -៩៤០ | -៨.៧៦៤ | -៣៣.២២៤ | ១៣.៩៨២ | -១៥.៤៥៦ |

*សញ្ញា (-) មានន័យថាសមត្ថភាពស្រូបយកកាបូន

# វិស័យសំណល់

ដើម្បីគណនាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយពីវិស័យសំណល់ ការសិក្សានេះប្រើប្រាស់គំរូ ExSS/waste ។ គំរូនេះអាចប្រើប្រាស់ដើម្បីពិពណ៌នាសកម្មភាពទាក់ទងនឹងសំណល់និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលរួមមានការបង្កើតនិងការគ្រប់គ្រងសំណល់រឹងមានប្រភពចេញពីវិស័យលំនៅដ្ឋាន ពានិជ្ជកម្ម ឧស្សាហ៍កម្ម និងសំណង់ ព្រមទាំង ការបង្កើតនិងការគ្រប់គ្រងសំណល់រាវមានប្រភពចេញពីវិស័យលំនៅដ្ឋាន និង ឧស្សាហ៍កម្ម ។ លទ្ធផលនៃការបង្កើតសំណល់និងបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយមានដូចខាងក្រោម៖

## ការបង្កើតសំណល់៖

ការសិក្សានេះសន្មត់ថាការបង្កើតសំណល់រឹងសម្រាប់មនុស្សម្នាក់ៗមានចំនួនដូចគ្នាទៅនឹងចំនួន នៃបណ្តាប្រទេសមានសេដ្ឋកិច្ចមធ្យមកម្រិតខ្ពស់ (១,១៦គីឡូក្រាមសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) ត្រឹមឆ្នាំ២០៣០និងដូចបណ្តាប្រទេសអភិវឌ្ឍ (២,១៣គីឡូក្រាមសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) ត្រឹមឆ្នាំ២០៥០។ ជាលទ្ធផល ការបង្កើតសំណល់រឹងក្នុងមួយឆ្នាំៗនឹងកើនឡើងពី ៣ (បី) លានតោននៅឆ្នាំ២០១០ រហូតដល់ ១០ (៤ដង) និង ១២ (ដប់ពីរ) លានតោន (១២ដង) នៅឆ្នាំ២០៣០ និង ២០៥០ រៀងៗខ្លួន។ ជម្រើសនៃការគ្រប់គ្រងគឺអនុវត្តក្នុងគោលបំណងកាត់បន្ថយបរិមាណបោះចោលសំណល់នៅទីលានសំរាម។ ចំណែកឯ ការបង្កើតសំណល់រាវក្នុងមួយឆ្នាំៗនឹងកើនឡើងពី ០,២១មម$^{៣}$ នៅឆ្នាំ២០១០ រហូតដល់ ០,៣១ (១,៥ដង) និង ០,៤៩មម$^{៣}$ (២,៣ដង) នៅឆ្នាំ២០៣០ និង២០៥០ រៀងៗខ្លួន។ ការសិក្សានេះសន្មត់ថា បរិមាណបង្កើតសំណល់មានចំនួនដូចគ្នាទាំងករណី BaU និង CM ។ តារាងទី១៨ បង្ហាញពីបរិមាណបង្កើតសំណល់នៅប្រទេសកម្ពុជា។

**តារាងទី១៨៖** បរិមាណបង្កើតសំណល់

| ការបង្កើតសំណល់រឹង (លានតោន/ឆ្នាំ) | ២០១០ | ២០៣០ | ២០៥០ |
|---|---|---|---|
| លំនៅដ្ឋាន | ១,៥៣ | ៤,១៦ | ១០,៣៤ |
| មណ្ឌលពានិជ្ជកម្ម | ០,៤៥ | ១,៧៨ | ៦,៩២ |
| ឧស្សាហ៍កម្ម | ០,៦៩ | ២,៩៥ | ១២,១៥ |
| សំណង់អាគារ | ០,២៦ | ១,១៨ | ៤,៧៣ |
| បរិមាណសរុប | ២,៩២ | ១០,០៧ | ៣៤,១៤ |
| ការបង្កើតសំណល់រាវ (មម$^{៣}$/ឆ្នាំ) | | | |
| លំនៅដ្ឋាន | ០,២០ | ០,២៧ | ០,៣២ |
| ឧស្សាហ៍កម្ម | ០,០១ | ០,០៤ | ០,១៧ |
| បរិមាណសរុប | ០,២១ | ០,៣១ | ០,៤៩ |

## បរិមាណបញ្ចេញឧស្ម័ននិងសក្តានុពលកាត់បន្ថយ៖

ដោយសារការរំពឹងថានឹងមានកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ចនៅឆ្នាំគោលដៅនោះ បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យសំណល់នឹងមានការកើនឡើងពីប្រហែល ១.៥៦៦$ktCO_2eq./year$ នៅឆ្នាំ២០១០ រហូតដល់ ៥.៧៣១ (៤ដង) និង ១៥.២១៦ $ktCO_2eq./year$ (១០ដង) នៅឆ្នាំ2030BaU និង 2050BaU រៀងៗខ្លួន។

ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការអនុវត្តវិធានការអភិវឌ្ឍន៍បញ្ចេញកាបូនតិចមួយចំនួនដូចជា៖ ការអនុវត្តគោលការណ៍ ៣Rs និងការចាប់យក $CH_4$ ពីទីលានសំណល់ជាដើមនោះ បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងថយចុះមកត្រឹមប្រហែល ៤.៩៨០ (៣ដង) និង ៩.៣៤១ $ktCO_2eq./year$ (៦ដង) នៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ ប្រការនេះមានន័យថាប្រហែល ១៣% និង ៣៩% នៃបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបនឹងអាចកាត់បន្ថយបាននៅឆ្នាំ2030CM និង 2050CM រៀងៗខ្លួន។ តារាងទី១៩ បង្ហាញពីបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង សក្តានុពលកាត់បន្ថយនៅក្នុងវិស័យសំណល់ ($ktCO_2eq./year$)។

**តារាងទី១៩៖** បរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសក្តានុពលកាត់បន្ថយ ($ktCO_2eq./year$)

| តាមវិស័យ/ឆ្នាំ [$ktCO_2eq./year$] | 2010 | 2030BaU | 2030CM | 2050BaU | 2050CM |
|---|---|---|---|---|---|
| លំនៅដ្ឋាន | ២៦២ | ៩៥១ | ៨២៦ | ២.៣២៦ | ១.៥៣៥ |
| មណ្ឌលពានិជ្ជកម្ម | ១៧៤ | ៦០៦ | ៥១៥ | ១.៧៧៤ | ១.១១៧ |
| ឧស្សាហ៍កម្ម | ១.១២៧ | ៤.១៦០ | ៣.៦២៧ | ១១.០៨២ | ៦.៦៦១ |
| សំណង់អាគារ | ៣ | ១៤ | ១២ | ៣៤ | ២៨ |
| បរិមាណបញ្ចេញ និង កាត់បន្ថយសរុប | ១.៥៦៦ | ៥.៧៣១ | ៤.៩៨០ | ១៥.២១៦ | ៩.៣៤១ |

ស្ថាប័នចូលរួមក្នុងការរៀបចំឯកសារនេះរួមមាន៖ ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកលនៃប្រទេសជប៉ុន និងវិទ្យាស្ថានជាតិសិក្សាបរិស្ថាននៃប្រទេសជប៉ុន។

## ទីប្រឹក្សា៖

| ឈ្មោះ | ស្ថាប័ន | តួនាទី |
|---|---|---|
| ឯ.ឧ. បណ្ឌិត ទិន ពន្លក | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃប្រទេសកម្ពុជា | អគ្គលេខាធិការ |
| សាស្ត្រាចារ្យ Yuzuru MATSUOKA | សាកលវិទ្យាល័យក្យូតូនៃប្រទេសជប៉ុន | សាស្ត្រាចារ្យ |
| លោកបណ្ឌិត Shuzo NISHIOKA | វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកលនៃប្រទេសជប៉ុន | ទីប្រឹក្សាជាន់ខ្ពស់ |

## ក្រុមការងារ៖

| ឈ្មោះ | ស្ថាប័ន | តួនាទី |
|---|---|---|
| លោកបណ្ឌិត ហាក់ ម៉ៅ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃប្រទេសកម្ពុជា និង សាកលវិទ្យាល័យក្យូតូនៃប្រទេសជប៉ុន | អនុប្រធាននាយកដ្ឋាន និង ជាអ្នកស្រាវជ្រាវ |
| លោកស្រី Tomoko ISHIKAWA | វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកលនៃប្រទេសជប៉ុន | លេខា |
| លោកបណ្ឌិត Junichi FUJINO | វិទ្យាស្ថានជាតិសិក្សាបរិស្ថាននៃប្រទេសជប៉ុន | អ្នកស្រាវជ្រាវជាន់ខ្ពស់ |
| លោកបណ្ឌិត Kei GOMI | វិទ្យាស្ថានជាតិសិក្សាបរិស្ថាននៃប្រទេសជប៉ុន | អ្នកស្រាវជ្រាវ |
| លោកស្រីបណ្ឌិត Tomoko HASEGAWA | វិទ្យាស្ថានជាតិសិក្សាបរិស្ថាននៃប្រទេសជប៉ុន | អ្នកស្រាវជ្រាវ |
| លោកស្រីបណ្ឌិត NGUYEN Thai Hoa | សាកលវិទ្យាល័យក្យូតូនៃប្រទេសជប៉ុន | អ្នកស្រាវជ្រាវ |

## អាស័យដ្ឋានទំនាក់ទំនង៖

លោកបណ្ឌិត **ហាក់ ម៉ៅ**

អ៊ីម៉ែល៖ maohakccd.se@gmail.com

**អាស័យដ្ឋាននៅកម្ពុជា៖** ក្រសួងបរិស្ថាន (អគារមរតកតេជោ) ដីឡូលេខ ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ (ខាងកើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)

**អាស័យដ្ឋាននៅជប៉ុន៖** Department of Environmental Engineering, Kyoto University C-cluster, Kyotodaigaku Katsura, Nishikyo-ku, Kyoto, 615-8540, JAPAN

**រួមគ្នាដើម្បីជម្រុញការអភិវឌ្ឍ**
**បញ្ចេញកាបូនតិចនៅកម្ពុជា**

IGES KYOTO UNIVERSITY NIES JAPAN

២០១៦០៣១៥